# ថ្លៃសេវាប្រចាំខែជំនួសប្រាក់តម្កល់ – ទម្រង់បែបបទផ្ដល់ព័ត៌មាន

## អ្នកអាចបង់ថ្លៃសេវាប្រចាំខែជំនួសឱ្យការបង់ប្រាក់តម្កល់បាន។

ថ្លៃសេវានេះមិនមែនជាប្រាក់តម្កល់ទេ ហើយនឹងមិនបង្វិលសងវិញ នៅពេលអ្នករើចេញពីទីតាំងឡើយ។ តាមរយៈការបង់ថ្លៃសេវានេះ ម្ចាស់ទីតាំងនឹងអនុញ្ញាតឱ្យអ្នករើចូលទីតាំងដោយមិនចាំបាច់បង់ប្រាក់តម្កល់។ ប្រសិនបើអ្នកមិនបង់ប្រាក់ទាំងអស់ ឬអ្នកធ្វើឱ្យខូចខាតបរិវេណហួសពីកម្រិតសឹករេចរឹលតាមការប្រើប្រាស់ធម្មតា ម្ចាស់ទីតាំង ក្រុមហ៊ុនធានារ៉ាប់រងរបស់ម្ចាស់ទីតាំង ឬអ្នកប្រមូលបំណុលអាចតម្រូវឱ្យអ្នកបង់ប្រាក់ដែលមិនទាន់បង់ រួមទាំងចំណាយថ្លៃជួសជុលលើការខូចខាតដែលហួសពីកម្រិតសឹករេចរឹលតាមការប្រើប្រាស់ធម្មតាក្នុងបរិវេណ។

## ច្បាប់រដ្ឋវ៉ាស៊ីនតោនអនុញ្ញាតឱ្យអ្នកជ្រើសរើស 3 ជម្រើសខុសៗគ្នា៖

(1) បង់ប្រាក់តម្កល់ពេញ នៅពេលចុះកិច្ចសន្យាជួល។

(2) បង់ប្រាក់តម្កល់ពេញ និងថ្លៃសេវារើចូលផ្សេងទៀតរហូតដល់ 3 ដំណាក់កាល ប្រសិនបើអាចអនុវត្តបាន (មើលព័ត៌មានលម្អិតបន្ថែមខាងក្រោម)។

- ច្បាប់ក្នុងតំបន់មួយចំនួនផ្ដល់រយៈពេលយូរជាងនេះ។

(3) បង់ថ្លៃសេវាប្រចាំខែពីការមិនយកប្រាក់តម្កល់ ជំនួសឱ្យការបង់ប្រាក់តម្កល់ ប្រសិនបើម្ចាស់ទីតាំងផ្ដល់ជម្រើសនេះ។ ប្រសិនបើអ្នកជ្រើសរើសជម្រើសនេះ អ្នកនឹងមិនបង់ប្រាក់តម្កល់ ឬថ្លៃជួលសម្រាប់ខែចុងក្រោយជាមុននោះទេ។ ថ្លៃសេវាប្រចាំខែរបស់អ្នកនឹងមានចំនួន $______________ បន្ថែមពីលើថ្លៃជួលប្រចាំខែរបស់អ្នក ជំនួសឱ្យការបង់ប្រាក់តម្កល់ និង/ឬថ្លៃជួលសម្រាប់ខែចុងក្រោយចំនួន $______________។

<u>ប្រសិនបើអ្នកជ្រើសរើសបង់ថ្លៃសេវាប្រចាំខែពីការមិនយកប្រាក់តម្កល់ ជំនួសឱ្យការបង់ប្រាក់តម្កល់ នេះគឺជាចំនួនដែលអ្នកនឹងត្រូវបង់ក្នុងរយៈពេលជួលទាំងមូល ធៀបនឹងការបង់ប្រាក់តម្កល់តែមួយលើក៖</u>

| | |
|---|---|
| ថ្លៃសេវាប្រចាំខែពីការមិនយកប្រាក់តម្កល់ដែលមិនបង្វិលសង៖<br>________________<br>ចំណាយសរុបលើថ្លៃសេវាប្រចាំខែក្នុងរយៈពេលជួលទាំងមូល៖<br>________________ | ប្រាក់តម្កល់តែមួយលើកដែលបង្វិលសង៖<br>________________ |

ក្នុងករណីដែលរយៈពេលជួលរបស់អ្នកបញ្ចប់ ហើយអ្នកមិនបានបង់ថ្លៃជួល ឬទឹកប្រាក់ផ្សេងទៀតដែលដល់ពេលកំណត់តាមកិច្ចសន្យាជួល ហើយអ្នកមិនបានបង់ថ្លៃជួសជុលការខូចខាតដែលហួសពីកម្រិតសឹករេចរឹលតាមការប្រើប្រាស់ធម្មតាក្នុងបរិវេណ នោះប្រាក់ធានារ៉ាប់រងនឹងបង់ប្រាក់ឱ្យម្ចាស់ទីតាំងជួលរហូតដល់៖

$_____________ សម្រាប់ថ្លៃជួល និងថ្លៃសេវាមិនទាន់បង់ និង

$_____________ សម្រាប់ការខូចខាត។

ធានារ៉ាប់រងសរុប៖ $_______________

ចំណុចសំខាន់៖ ប្រសិនបើអ្នកជ្រើសរើសបង់ថ្លៃសេវាប្រចាំខែជំនួសឱ្យការបង់ប្រាក់តម្កល់៖

(1) អ្នកមិនមែនជាភាគីដែលត្រូវបានធានារ៉ាប់រងតាមគោលការណ៍ធានារ៉ាប់រងដែលទិញដោយម្ចាស់ទីតាំងដោយប្រើថ្លៃជួលរបស់អ្នកទេ

(2) អ្នកមិនមែនជាអ្នកទទួលផលពីប្រាក់ធានារ៉ាប់រង ឬអត្ថប្រយោជន៍នៃការធានារ៉ាប់រងណាមួយតាមគោលការណ៍ធានារ៉ាប់រងដែលម្ចាស់ទីតាំងទិញដោយប្រើថ្លៃជួលរបស់អ្នក និង

(3) អ្នកនៅតែមានកាតព្វកិច្ចបង់ថ្លៃជួល និងប្រាក់ទាំងអស់តាមកិច្ចសន្យាជួល រួមទាំងចំណាយលើការខូចខាតដែលហួសពីកម្រិតសឹករេចរឹលតាមការប្រើប្រាស់ធម្មតាក្នុងបរិវេណ។

ម្ចាស់ទីតាំងអាចស្វះស្វែងយកប្រាក់ពីអ្នក មុនពេលដាក់ស្នើសុំប្រាក់ធានារ៉ាប់រងពីក្រុមហ៊ុនធានារ៉ាប់រង។ ប្រសិនបើអ្នកមិនអាចបង់ថ្លៃជួលដែលមិនទាន់បង់ ឬប្រាក់មិនទាន់បង់ផ្សេងទៀត ឬចំណាយលើការខូចខាតដែលហួសពីកម្រិតសឹករេចរឹលតាមការប្រើប្រាស់ធម្មតាក្នុងបរិវេណឱ្យម្ចាស់ទីតាំង ហើយក្រុមហ៊ុនធានារ៉ាប់រងបង់ប្រាក់ឱ្យម្ចាស់ទីតាំងជំនួសវិញ ក្រុមហ៊ុនធានារ៉ាប់រងនោះអាចស្វះស្វែងយកប្រាក់សំណងដែលបានបង់ឱ្យម្ចាស់ទីតាំងពីអ្នកវិញ។

ប្រសិនបើអ្នកជ្រើសរើសបង់ថ្លៃសេវាប្រចាំខែជំនួសឱ្យការបង់ប្រាក់តម្កល់ អ្នកត្រូវបានអនុញ្ញាតឱ្យបង់ប្រាក់តម្កល់ទៅម្ចាស់ទីតាំងចំនួន $_________ នៅពេលណាក៏បាន ហើយឈប់បង់ថ្លៃសេវាប្រចាំខែ ចាប់ពីខែក្រោយពីការបង់ប្រាក់តម្កល់នោះរួច។